

# Medical Baseline Program

**ដាក់ពាក្យសុំថ្ងៃនេះ**

ទទួលបានជំនួយបន្ថែមពី PG&E ប្រសិនបើអ្នកពឹងផ្អែកលើថាមពលសម្រាប់តម្រូវការផ្នែកវេជ្ជសាស្ត្រជាក់លាក់។

## អត្ថប្រយោជន៍

- ✓ **ការសន្សំសំចៃផ្នែកហិរញ្ញវត្ថុ៖** ទទួលបានចំណែកថាមពលប្រចាំខែបន្ថែម ឬការបញ្ចុះតម្លៃដោយផ្អែកលើអត្រារបស់អ្នក។
- ✓ **ជំនួយអតិថិជន៖** អ្នកអាចទទួលបានការជូនដំណឹងបន្ថែមមុនការផ្តាច់ចរន្តអគ្គិសនីដើម្បីសុវត្ថិភាពសាធារណៈ (PSPS)។ ប្រសិនបើអ្នកមិនឆ្លើយតបទេ យើងនឹងធ្វើការជូនដំណឹងបន្ថែមជារៀងរាល់ម៉ោង ឬទាក់ទងអ្នកដោយផ្ទាល់ រហូតដល់យើងទាក់ទងអ្នកបាន។

### អ្នកអាចមានសិទ្ធិទទួលបានប្រសិនបើអ្នក៖

- ប្រើប្រាស់ឧបករណ៍វេជ្ជសាស្ត្រដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់
- មានស្ថានភាពវេជ្ជសាស្ត្រដែលកំពុងដំណើរការជាមួយនឹងតម្រូវការកម្តៅ ឬត្រជាក់ជាក់លាក់

### ឧបករណ៍ដែលមានសិទ្ធិទទួលបានមួយចំនួនរួមមាន៖

- រទេះរុញប្រើម៉ូទ័រ
- ម៉ាស៊ីន CPAP
- ឧបករណ៍ដកដង្ហើម
- ម៉ាស៊ីនលាងឈាម

**ស្វែងយល់បន្ថែមទៀត**

សម្រាប់បញ្ជីរាយឈ្មោះឧបករណ៍ និងស្ថានភាពវេជ្ជសាស្ត្រដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ សូមចូលទៅ pge.com/medicalbaseline ឬហៅទៅលេខ **1-800-743-5000**។ ភាពមានសិទ្ធិទទួលបានគឺមិនផ្អែកលើប្រាក់ចំណូលទេ។

# របៀបចុះឈ្មោះ

## 1 ដាក់ពាក្យតាមអ៊ីនធឺណិត
បំពេញពាក្យសុំតាម [pge.com/medicalbaseline](pge.com/medicalbaseline)។

## 2 ទទួលបានលេខកូដបញ្ជាក់តាមរយៈអ៊ីមែល
ចែករំលែកលេខកូដរបស់អ្នកជាមួយនឹងគ្រូពេទ្យរបស់អ្នក។ ពួកគេនឹងត្រូវបញ្ចូលព័ត៌មានតាមអ៊ីនធឺណិតសម្រាប់ពាក្យសុំរបស់អ្នក។

## 3 ឲ្យគ្រូពេទ្យរបស់អ្នកបំពេញពាក្យសុំរបស់អ្នក
គ្រូពេទ្យរបស់អ្នកនឹងបញ្ជាក់ប្រាប់ ប្រសិនបើអ្នកមានសិទ្ធិទទួលបានសម្រាប់កម្មវិធី។ បន្ទាប់មកពួកគេនឹងប្រគល់ពាក្យសុំតាមអ៊ីនធឺណិតរបស់អ្នកទៅ PG&E វិញ។

អ្នកក៏អាចបោះពុម្ពទម្រង់បំពេញពាក្យសុំដោយចូលទៅ [pge.com/medicalbaseline](pge.com/medicalbaseline) បានផងដែរ។ គ្រូពេទ្យរបស់អ្នកនឹងត្រូវបំពេញក្រដាសពាក្យសុំរបស់អ្នក។

**ការដាក់ពាក្យសុំតាមសំបុត្រទៅ៖**

PG&E Billing Center
Medical Baseline
P.O. Box 8329
Stockton, CA 95208

ដើម្បីស្នើសុំក្រដាសពាក្យសុំជាអក្សរធំ ឬជាអក្សរស្ទាបសម្រាប់ជនពិការភ្នែក សូមហៅទៅលេខ **1-800-743-5000**។

# ធនធានបន្ថែមសម្រាប់អតិថិជន Medical Baseline

## នៅមុនពេលដាច់ចរន្តអគ្គិសនី PSPS៖



- មើលថាតើអ្នកមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ម៉ាស៊ីនភ្លើងជំនួស អាគុយចល័ត ឬកុងទ័រផ្ទេរថាមពលបម្រុង ដើម្បីផ្តល់ថាមពលទៅឧបករណ៍នានាអំឡុងពេលដាច់ចរន្តអគ្គិសនីដែរឬទេ។ [pge.com/backuppower](pge.com/backuppower)
- រក្សាទុកលេខ **1-800-743-5002** នៅក្នុងទូរសព្ទរបស់អ្នក ដូច្នេះអ្នកនឹងស្គាល់លេខរបស់យើងនៅពេលយើងទាក់ទងអ្នក។

## អំឡុងពេលការផ្តាច់ចរន្តអគ្គិសនី PSPS សូមចូលទៅ [pge.com/pspsresources](pge.com/pspsresources) ដើម្បី៖

- កំណត់ទីតាំងនៃមជ្ឈមណ្ឌលធនធានសហគមន៍ដើម្បីសាកឧបករណ៍របស់អ្នក និងទទួលបានការផ្គត់ផ្គង់។
- ស្វែងរករថយន្តសម្រាប់ជនពិការ និងជម្រើសសណ្ឋាគារ។
- ទទួលការជំនួសអាហារពីឃ្លាំងផ្ទុកអាហារក្នុងមូលដ្ឋាន។

សម្រាប់ជំនួយផ្នែកបកប្រែច្រើនជាង 240+ ភាសា សូមហៅទូរសព្ទទៅ PG&E តាមលេខ **1-866-743-6589**។ ដើម្បីទទួលការប្រាស្រ័យទាក់ទងជាអក្សរធំ ឬអក្សរស្ទាប សូមហៅទូរសព្ទទៅលេខ **1-800-743-5000**។

វិធានការមួយចំនួនដែលមាននៅក្នុងឯកសារនេះ ត្រូវបានចាត់ទុកជាវិធានការប្រុងប្រយ័ត្នទុកជាមុនបន្ថែម ក្នុងគោលបំណងកាត់បន្ថយហានិភ័យនៃភ្លើងឆេះព្រៃបន្ថែមទៀត។ "PG&E" សំដៅដល់ Pacific Gas and Electric Company ដែលជាបុត្រសម្ព័ន្ធមួយរបស់ក្រុមហ៊ុនសាជីវកម្ម PG&E ។ ©2023 Pacific Gas and Electric Company ។ រក្សាសិទ្ធគ្រប់យ៉ាង។ CCC-0623-6536។ 05/16/2023។